# Long Beach Energy Resources Coronavirus (COVID-19) Response & Support

## ក្រុមឡុងប៊ិចផ្នែកធនធានថាមពល ការឆ្លើយតប និងការគាំទ្រ ក្នុងពេលមេរោគកូរូណាវ៉ាយរូស (COVID-19)

នាយកដ្ឋានធនធានថាមពល (ER) ប្ដេជ្ញាចិត្តផ្ដល់សេវាកម្ម ហ្គាសធម្មជាតិ ប្រកបដោយសុវត្ថិភាព និងតម្លៃសមរម្យ និងអាចទុកចិត្តបាន ដល់អតិថិជនទាំងអស់។ យើងកំពុងតាមដានយ៉ាងជិតដល់ ចំពោះជំងឺផ្ដាសាយធំកូវិដ១៩ COVID-19 ជាមួយភ្នាក់ងារសុខភាពរដ្ឋ និងសហព័ន្ធ។ ស្របជាមួយលទ្ធផល ដែលយើងកំពុងធ្វើការផ្លាស់ប្ដូរជាបណ្ដោះអាសន្ន ចំពោះការប្រតិបត្តិសេវាអថិជនមួយចំនួនរបស់យើង ឱ្យសមស្របតាមការណែនាំពីមន្ត្រីសុខភាពសាធារណៈ និងមជ្ឈមណ្ឌលត្រួតពិនិត្យ និងបង្ការជំងឺ (CDC)។ ទាំងនេះ មានរួមបញ្ចូល :

- នៅតែបន្តរដាក់ពេលកំណត់ណាត់ជួប ចំពោះសេវាកម្មជាចាំបាច់ និងសេវាកម្មហ្គាសធម្មជាតិ មានរួមទាំង ធ្វើសេចក្ដីរាយការណ៍អំពីការសង្ស័យលេចធ្លាយជាតិហ្គាស ការពិនិត្យរកមើលផ្សែងពុលឧស្ម័ន ការបើកម៉ែត្រហ្គាសឡើងវិញឱ្យមានដំណើរការ ហ្គាសធម្មជាតិរលត់ និងត្រូវការបញ្ឆេះភ្លើងហ្គាសឡើងវិញ។

- ការផ្អាកជាបណ្ដោះអាសន្ន នៃការឆែកឆេរឧបករណ៍ នឹងការហៅទូរស័ព្ទដែលមិនចាំបាច់ ឧទាហរណ៍ កំដៅអាងហែលទឹក ចង្ក្រានអាំសាច់ និងរណ្ដៅភ្លើង។

- នៅពេលសេវាចុះទៅជួបជាបន្ទាន់ បុគ្គលិក ER ផ្នែកសេវាកម្ម អាចស្នើសុំអតិថិជនឱ្យទៅបន្ទប់ផ្សេងទៀត ដើម្បីរក្សាចម្ងាយ ៦ ហ្វីតពីគ្នា តាមគោលការណ៍ណែនាំរបស់ មជ្ឈមណ្ឌលត្រួតពិនិត្យ និងបង្ការជំងឺ (CDC)។

សូមប្រើប្រាស់បណ្ដាញនេះ this link ដើម្បីទទួលបាននូវព័ត៌មានថ្មីៗ បំផុត នៅពេលដែលស្ថានភាព COVID-19 កូវិដ១៩ នេះបន្តអភិវឌ្ឍ។

## តើធនធានថាមពលនេះ  កំពុងធ្វើអ្វីខ្លះ  ដើម្បីជួយទៅដល់អតិថិជន

ផ្នែកធនធានថាមពល ឥឡូវនេះ នឹងផ្តល់ការស្តារឡើងវិញនូវសេវាកម្មហ្គាស ទៅដល់អតិថិជន ដែលបច្ចុប្បន្នត្រូវបានបិទផ្តាច់ហ្គាស ដោយសាការមិនបង់ប្រាក់ ( ប្រមាណ ៧៤ នៅពេលនេះ) ក្នុងកំឡុងពេលស្ថានភាពអាសន្ន COVID-19 កូវិឌ-១៩ មានដូចតទៅ :
១. អតិធិជនត្រូវទូរស័ព្ទទៅ មឈ្ឍមណ្ឌធនធានថាមពល (ER) តាមលេខ (562) 570- 5700 ហើយស្នើសុំឱ្យមានសេវាកម្មហ្គាស របស់ពួកគេឡើងវិញ ( ER នឹងមិនទូរស័ព្ទទៅអតិជន ដើម្បីបើកសេវាកម្មហ្គាស របស់ពួកគេឡើងវិញទេ) ។

២. តំណាងការិយាល័យ ER ផ្នែកទំនាក់ទំនង និងធ្វើការជាមួយអតិថិជន ដើម្បីកំណត់ពេលវេលា តំឡើងសេវាកម្មហ្គាសឡើងវិញ តាមរយះពេល ដែលបុគ្គលិក ER អាចផ្តល់សេវាកម្មជូនបាន ។

៣. តំណាងការិយាល័យ  ER ផ្នែកទំនាក់ទំនង នឹងធ្វើការជាមួយអតិថិជន ដើម្បីរៀបចំគម្រោងបង់ថ្លៃហ្គាសរបស់ពួកគេ ដែលនៅសល់ ក្នុងពេលបច្ចុប្បន្ននេះ ។

៤. សេវាកម្មហ្គាស សម្រាប់ផ្តល់ដល់អតិថិជន នឹងត្រូវស្តារឡើងវិញតាមការគ្រោងទុក ។